Disability Rights California

បណ្ដាញការពារ និង គាំទ្រនៃរដ្ឋកាលីហ្វ័រញ៉ា

អាស័យដ្ឋានគេហទំព័រ: www.disabilityrightsca.org

ទូរស័ព្ទឥតគិតថ្លៃ: (800) 776-5746

TTY: (800) 719-5798

---

## សេចក្ដីជូនដំណឹងជាសាធារណៈ: កម្មវត្ថុ: នីតិវិធីបណ្ដឹងសាទុក្ខសម្រាប់

## DISABILITY RIGHTS CALIFORNIA

## របៀបដាក់ពាក្យបណ្ដឹងសាទុក្ខ

លោកអ្នក អាចនឹងដាក់ពាក្យបណ្ដឹងសាទុក្ខមួយបាន ក្នុងករណីដូចខាងក្រោមនេះ៖

- លោកអ្នក បានស្នើសុំជំនួយ Disability Rights California ប៉ុន្តែត្រូវបានគេជម្រាបប្រាប់ថា លោកអ្នកមិនអាចទទួលជំនួយបានទេ
- បច្ចុប្បន្ន លោកអ្នកកំពុងទទួលបានជំនួយពី Disability Rights California តែមិនពេញចិត្តចំពោះជំនួយនេះ ឬ
- ជំនួយដែលលោកអ្នកកំពុងទទួលបាននោះ បានផុតរលត់ទៅហើយៗ Disability Rights California បានបដិសេធមិនបន្តផ្ដល់ជំនួយតទៅទៀត។

ដើម្បីដាក់ពាក្យប្ដឹងសាទុក្ខមួយ លោកអ្នកអាចអនុវត្តតាមជំហានដូចខាងក្រោមនេះ៖

**ជំហានទី1 (តាមជម្រើស ឬ តាមចិត្ត) ពិគ្រោះពិភាក្សាលើបញ្ហាមិនយល់ស្របជាមួយនឹងមន្ត្រីរបស់ Disability Rights California Employee។**

លោកអ្នក អាចចង់ពិគ្រោះគ្នាលើបញ្ហានេះជាមួយនឹងមនុស្សដែលជាបុគ្គលិករបស់ Disability Rights California។ លោកអ្នក មិនចាំបាច់ត្រូវធ្វើដូច្នេះទេ។

**ជំហានទី2 នាយកប្រតិបត្តិរបស់ Disability Rights California**

លោកអ្នក អាចនឹងដាក់ពាក្យប្ដឹងសាទុក្ខមួយបានដោយផ្ទាល់ជាមួយនឹងនាយកប្រតិបត្តិ Disability Rights California ក្នុងរយៈពេល 30ថ្ងៃ ក្រោយពី Disability Rights California បានធ្វើនូវសេចក្ដីសម្រេចចិត្តដែលលោកអ្នកមិនចង់បាន។

លោកអ្នក អាចដាក់ពាក្យប្តឹងសាទុក្ខបាន ដោយប្រើប្រាស់ទម្រង់បែបបទដែលមានភ្ជាប់នេះ ដោយការសរសេរបណ្តឹងសាទុក្ខរបស់ខ្លួនក្រដាសផ្សេងទៀត ឬ តាមរយៈការហៅទូរស័ព្ទទៅកាន់ Disability Rights California។ សូមបញ្ជូនបណ្តឹងសាទុក្ខរបស់លោកអ្នកជូនចំពោះ៖

Executive Director
Disability Rights California
1831 K Street
Sacramento, CA 95811
(916) 504-5800 (ការទូរស័ព្ទហៅឲ្យយក ត្រូវបានគេទទួល) or (800) 776-5746
Fax: (916) 504-5809
TTY: (800) 719-5798
E-mail: executivedirector@disabilityrightsca.org

នាយកប្រតិបត្តិ នឹងពិនិត្យមើលលើបណ្តឹងសាទុក្ខរបស់លោកអ្នក ហើយផ្តល់ជូនលោកអ្នកនូវសេចក្តីសម្រេចជាផ្លូវការមួយក្នុងរយៈពេល 30ថ្ងៃ ប្រសិននាយក/នាយិកា នោះមិនប្រាប់ទៅលោកអ្នកថា គាត់ចាំបាច់ត្រូវការពេលវេលាបន្ថែមទេនោះ។

## ជំហានទី3 ក្រុមប្រឹក្សានាយកនៃ Disability Rights California

ក្នុងករណីលោកអ្នក មិនយល់ស្របនឹងសេចក្តីសម្រេចរបស់នាយក/នាយិកាទេនេះ លោកអ្នកអាចនឹងស្នើសុំឲ្យមានការពិនិត្យមើលឡើងវិញមួយដោយគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សារបស់ Disability Rights California ក្នុងរយៈពេល 30ថ្ងៃ ក្រោយពីការសេចក្តីសម្រេចរបស់នាយក/នាយិកានេះ។

លោកអ្នក អាចស្នើសុំឲ្យមានការពិនិត្យមើលឡើងវិញបាន ដោយប្រើប្រាស់ទម្រង់បែបបទដែលមានភ្ជាប់នេះ ដោយការសរសេរបណ្តឹងសាទុក្ខរបស់ខ្លួនក្រដាសផ្សេងទៀត ឬ តាមរយៈការហៅទូរស័ព្ទទៅកាន់ Disability Rights California។ សូមបញ្ជូនសំណើរបស់លោកអ្នកជូនចំពោះ៖

President, Board of Directors
Disability Rights California
1831 K Street
Sacramento, CA 95811
(916) 504-5800 (ការទូរស័ព្ទហៅឲ្យយក ត្រូវបានគេទទួល) or (800) 776-5746
Fax: (916) 504-5809
TTY: (800) 719-5798
E-mail: board@disabilityrightsca.org

គណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សានេះ នឹងពិនិត្យមើលឡើងវិញលើសំណើរបស់លោកអ្នក ហើយចេញឲ្យលោកអ្នកនូវសេចក្តីសម្រេចជាផ្លូវការមួយក្នុងរយៈពេល 30ថ្ងៃ ប្រសិនប្រធានក្រុមប្រឹក្សានេះមិនប្រាប់ទៅលោកអ្នកថា គាត់ចាំបាច់ត្រូវការពេលវេលាបន្ថែមទេនោះ។ សេចក្តីសម្រេចរបស់គណៈកម្មាធិការប្រតិបត្តិ គឺជាសេចក្តីសម្រេចចុងក្រោយរបស់ Disability Rights California។

# ទម្រង់បណ្តឹងសាទុក្ខជាបុគ្គល

ដើម្បីដាក់ពាក្យប្តឹងសាទុក្ខមួយ លោកអ្នកអាចប្រើប្រាស់នូវទម្រង់បែបបទនេះ សរសេរបណ្តឹងសាទុក្ខរបស់លោកអ្នកលើក្រដាសមួយផ្សេងទៀត ឬ ហៅទូរស័ព្ទលេខ: (916) 504-5800 (ការទូរស័ព្ទហៅឲ្យយក ត្រូវបានគេទទួល) ឬ (800) 776-5746 ហើយសាកសួរទៅបុគ្គលិករបស់ Disability Rights California ដើម្បីសុំឲ្យជួយលោកអ្នកក្នុងការសរសេរបណ្តឹងសាទុក្ខរបស់ខ្លួន។ លើសពីនេះ លោកអ្នកអាចទូរស័ព្ទទាក់ទងយើងខ្ញុំតាមបណ្តាញ TTY ដែលមានលេខ: (800) 719-5798 សូមផ្ញើទូរសារតាមលេខ: (916) 504-5809 ឬ ផ្ញើសាអេឡិចត្រូនិក (e-mail) ទៅកាន់អាស័យដ្ឋាន: executivedirector@disabilityrightsca.org។

ឈ្មោះរបស់លោកអ្នក:

អាស័យដ្ឋានរបស់លោកអ្នក:

លេខទូរស័ព្ទរបស់លោកអ្នកសម្រាប់ទាក់ទងនៅពេលថ្ងៃ: (     )

អាស័យដ្ឋានអ៊ីម៉ែលរបស់លោកអ្នក:

ប្រសិនបើលោកអ្នក កំពុងជួយមនុស្សម្នាក់ឲ្យដាក់ពាក្យបណ្តឹងសាទុក្ខ ឈ្មោះរបស់ពួក:

សូមមេត្តាពន្យល់អំពីមូលហេតុដែលលោកអ្នកកំពុងដាក់ពាក្យប្តឹងសាទុក្ខ:

តើលោកអ្នក មានបំណងចង់ឲ្យ Disability Rights California មានដំណោះស្រាយយ៉ាងដូចម្តេច?